# សហគមន៍ព្រៃឈើខេត្តសៀមរាប



## ដើម្បីទាំងអស់គ្នាចូលរួមគ្រប់គ្រង

ឧបត្ថម្ភដោយកម្មវិធី SEILA / ADESS

# លក្ខណៈសំខាន់ៗនៃការអភិវឌ្ឍន៍សហគមន៍ព្រៃឈើ

- មានការចូលរួមពីសហគមន៍មូលដ្ឋាន ។
- មានការគាំទ្រពីរដ្ឋអំណាចមូលដ្ឋាន, ស្ថាប័នជំនាញ ,អង្គការ..
- ធនធានពីព្រៃឈើសហគមន៍ បំរើដល់សហគមន៍មូលដ្ឋាន ។



## ទស្សនៈសំខាន់ៗនៃសហគមន៍ព្រៃឈើ



## អ្វីទៅជាសហគមន៍ព្រៃឈើ ?

-សហគមន៍ព្រៃឈើគឺជាបណ្តុំមនុស្សគ្រប់ស្រទាប់វណ្ណៈរួមគ្នាបង្កើតសហគមន៍ព្រៃឈើឡើង ដើម្បីគ្រប់គ្រង ថែរក្សា ការពារ ដាំដុះ និងប្រើប្រាស់ព្រៃឈើអោយមាននិរន្តរភាព ។
- សហគមន៍ព្រៃឈើគឺជាទំនាក់ទំនងរវាងមនុស្សនិងពៃឈើ ។

## មូលហេតុនៃការបង្កើតសហគមន៍ព្រៃឈើ

- កាត់បន្ថយនិងលប់បំបាត់នូវការបំផ្លេចបំផ្លាញធនធានព្រៃឈើ
- កែលំអរព្រៃរិចរិល និង គ្រប់គ្រងព្រៃឈើដែលមានស្រាប់
- ថែរក្សាទំនៀមទំលាប់ ប្រពៃណីរបស់ប្រជាជនដែលទាក់ទងទៅនិងព្រៃឈើ
- ធានាបាននូវការគ្រប់គ្រងធនធានព្រៃឈើ ប្រកបដោយប្រសិទ្ធិភាពខ្ពស់
- លើកកំពស់ជីវភាពប្រចាំថ្ងៃរបស់ប្រជាជន តាមរយៈផលិតផលព្រៃឈើ

## សារៈសំខាន់នៃការបង្កើតសហគមន៍ ព្រៃឈើ

- បំពេញតំរូវការប្រើប្រាស់ផល-អនុផលព្រៃឈើជាប្រចាំ ដូចជា ឈើសំណង់ សំភារៈកសិកម្ម អុស វល្លិ៍ ចរឹង បន្លែ ផ្លែឈើ ផ្សិត ឱសថ ...
- ធានាប្រភពទឹក សំរាប់ប្រើប្រាស់ និងកសិកម្ម
- បរិស្ថានធម្មជាតិល្អ សំរាប់ការរស់នៅ

## លក្ខណៈវិនិច្ឆ័យក្នុងការបង្កើតសហគមន៍ព្រៃឈើ

- មានការចូលរួមពីប្រជាពលរដ្ឋមូលដ្ឋាន
- មានការចាប់អារម្មណ៍និងគាំទ្រពីរដ្ឋអំណាចមូលដ្ឋាន
- គ្មានជំលោះក្នុងការកាន់កាប់ដីព្រៃ

# ដំណើរការរៀបចំសហគមន៍ព្រៃឈើ

ជ្រើសរើសទីតាំង

⇩

ករណីសិក្សា

⇩

ការពិភាក្សា

⇩

សិក្ខាសាលា

⇩

ផែនទី

⇩

លក្ខន្តិកៈ

⇩

ផែនការគ្រប់គ្រង

# ១. ការជ្រើសរើសទីតាំង

- មានការចាប់អារម្មណ៍ ឬ ស្នើសុំពីសហគមន៍មូលដ្ឋាន
- តំបន់ដែលមានប្រព័ន្ធគ្រប់គ្រងបែបទំនៀមទំលាប់
- តំបន់ដែលគ្មានជំលោះក្នុងការកាន់កាប់ដីធ្លី .....
- អ្នកប្រើប្រាស់ធនធានទាំងអស់ស្ថិតនៅក្នុងសហគមន៍ តែមួយ

# ២. ការសិក្សា

- ប្រវត្តិព្រៃឈើ
- ការប្រើប្រាស់ដីធ្លី និង កម្មសិទ្ធិដីធ្លី
- ការប្រើប្រាស់ធនធានព្រៃឈើ
- ប្រព័ន្ធគ្រប់គ្រងតាមបែបទំនៀមទំលាប់
- ជំលោះនៅក្នុងការប្រើប្រាស់ធនធានព្រៃឈើ
- ដំណោះស្រាយដែលត្រូវអនុវត្តដោយសហគមន៍

# ៣. ការពិភាក្សា

- ពិភាក្សាដាច់ដោយឡែកជាមួយអ្នកប្រើប្រាស់ ព្រៃឈើផ្សេងៗគ្នា
- បញ្ហាសំរាប់ធ្វើការពិភាក្សា រួមមានៈ នរណាប្រើប្រាស់ព្រៃឈើ ? សំរាប់គោល បំណងអ្វី កំរិតនៃការទាញយកផល ព្រៃឈើ ផ្ទៃដីសរុប ព្រំប្រទល់ បញ្ហានានា និង ជំរើសនៃការគ្រប់គ្រង ។
- ជ្រើសរើសតំណាងក្រុមដែលមានការចាប់អារម្មណ៍

## ៤. សិក្ខាសាលា

រាល់អ្នកប្រើប្រាស់ព្រៃឈើទាំងអស់ ត្រូវចូលរួមក្នុង អង្គសិក្ខាសាលា ។ គោលបំណងរបស់សិក្ខាសាលាគឺ ត្រូវឈានទៅរកគំនិតស្របគ្នាមួយ លើបញ្ហាព្រំប្រទល់ព្រៃឈើសហគមន៍ សកម្មភាពគ្រប់គ្រង ការបែងចែកដីព្រៃ ការបង្កើតគណៈកម្មការគ្រប់គ្រងព្រៃឈើ ការបែងចែក ផលប្រយោជន៍ និង ការបង្កើត លក្ខន្តិកៈ ។

## ៥. ផែនទី

- ការគូសផែនទីពង្រាងតាមបែបចូលរួម ត្រូវបានរៀប ចំឡើងដោយមានការចូលរួមពីប្រជាជនមូលដ្ឋាន ។
- ផែនទីបច្ចេកទេសដែលប្រើប្រាស់ GPS ត្រូវបានរៀបចំ និងពិភាក្សាជាមួយប្រជាជនមូលដ្ឋានដោយ មានការពិនិត្យជាក់ស្តែងនៅតាមតំបន់ព្រៃឈើ ។

## ៦. លក្ខន្តិកៈ

- លក្ខន្តិកៈត្រូវបានរៀបចំឡើងដោយប្រជាជនមូលដ្ឋាន ដោយមានការ សម្របសម្រួលពីមន្ត្រីជំនាញ
- លក្ខន្តិកៈផ្តោតលើការប្រើប្រាស់ព្រៃឈើ សកម្មភាព គ្រប់គ្រង តួនាទីរបស់ គណៈកម្មការព្រៃឈើ ការ បែងចែកផលប្រយោជន៍ ...
- លក្ខន្តិកៈ ត្រូវផ្អែកលើស្ថានភាពព្រៃឈើដ៏ជាក់លាក់
- លក្ខន្តិកៈ ត្រូវបានពិនិត្យសារឡើងវិញ ជាមួយ សហគមន៍ ហើយលក្ខន្តិកៈនោះត្រូវបានយល់ច្បាស់ និងទទួលយកដោយសហគមន៍
- លក្ខន្តិកៈត្រូវបានដាក់ជូនពិនិត្យ និងសំរេចទៅរដ្ឋបាលខេត្តតាមរយៈអាជ្ញាធរពាក់ព័ន្ធនានា

# ៧. ផែនការគ្រប់គ្រង

ផែនការនេះត្រូវបានរៀបចំជាមួយសហគមន៍ បន្ទាប់ពី ធ្វើការវិភាគ ទៅលើតម្រូវ ការនានារបស់អ្នកប្រើប្រាស់ ស្ថានភាពព្រៃ និងគោរពលក្ខន្តិកៈនៃការគ្រប់គ្រងព្រៃឈើ សហគមន៍ ។ ការរៀបចំផែនការគ្រប់គ្រោងធ្វើឡើងពីសហគមន៍មូលដ្ឋាន ដោយមានការសំរបសំរួលពីមន្ត្រីជំនាញ ហើយមានការទទួលស្គាល់ ពីស្ថាប័នពាក់ព័ន្ធមួយចំនួន ។

# ដំណើរការរៀបចំផែនការគ្រប់គ្រងសហគមន៍ព្រៃឈើ

**ដំណើរការប្រមូលព័ត៌មាន**

-ពិនិត្យការសិក្សា.លក្ខន្តិកៈ. ផែនទី. ព្រំប្រទល់ . ស្ថិតិ . ខ្សែមេត្រ . ត្រីវិស័យ . ថ្នាំលាប. តារាងសារពើភណ្ឌ . ការទទួលខុសត្រូវ . កំណត់ពេលវេលា .....។

↓

**ជ្រើសរើសគណៈកម្មការ**

-ជ្រើសរើសក្រុមអ្នកប្រើប្រាស់ពី៣០-៥០នាក់ ( ស្រី៣០% ).
-បង្ហាញពីគោលបំណងនៃ ការធ្វើផែនការគ្រប់គ្រង( ប្រើប្រាស់.គ្រប់គ្រង.អភិរក្ស...)
-ដំណើការអនុវត្តន៍សហគមន៍- ដំណើរការធ្វើផែនការគ្រប់គ្រង
-ជ្រើសរើសតំណាងក្រុមអ្នកប្រើប្រាស់ពី១៥-២០នាក់

Tool:Formal discussion
ពិភាក្សា .កសាងទំនុកចិត្ត

↓

**បណ្តុះបណ្តាល**

| | |
|---|---|
| -សារពើភ័ណ្ឌ -ផ្ទៀងផ្ទាត់តំបន់<br>-ផែនទីដោយមានការចូលរួម<br>-បែងចែកតំបន់អនុតំបន់ -សរសេរផែនការគ្រប់គ្រង | Tool<br>-ពិភាក្សា. បទបង្ហាញ<br>-Game |

↓

**ផែនទី**

| | |
|---|---|
| -គូសផែនទីដោយមានការចូលរួម<br>-កំនត់ធនធានសំខាន់ៗ | Tool<br>-ពិភាក្សា . សំភាសន៍ពាក់កណ្តាលផ្លូវការ<br>ពង្រាងផែនទី .បច្ចេកទេស GPS . GIS |

↓

**បែងចែកតំបន់អនុតំបន់**

| | |
|---|---|
| -បែងចែកតំបន់អនុតំបន់ដោយផ្អែកលើគុណភាពព្រៃ<br>គោលបំណងនៃការប្រើប្រាស់<br>-កំនត់ធនធានដែលមានក្នុងតំបន់អនុតំបន់និងប្រវត្តិ<br>-ការគ្រប់គ្រង.ការប្រើប្រាស់( តំបន់អនុតំបន់) | Tool<br>-ពិភាក្សា . សំភាសន៍ |

↓

**អង្កេតផ្ទៀងផ្ទាត់តំបន់អនុតំបន់**

| | |
|---|---|
| -ពិនិត្យតំបន់អនុតំបន់( ប្រភេទឈើ.ដំណុះ . ដី )<br>-ពិភាក្សាព្រំប្រទល់តំបន់អនុតំបន់<br>-ពំនូសកាត់តំបន់អនុតំបន់ ( Transect Work ) | Tool<br>-អង្កេតផ្ទាល់. ពំនូសកាត់តំបន់.<br>ពិភាក្សា.សំភាសន៍. GPS.GIS |

↓

**សារពើភណ្ឌ**

-ពិនិត្យផែនទី.ពំនូសកាត់តំបន់. ដើម្បីកំនត់ទីតាំងឡូតិ៍និងចំនួនឡូតិ៍
-ដាក់តាំងឡូតិ៍ធំ ( ១០ម x ១០ម ) រាប់រាប់ឈើខ្ពស់ជាង២ម( កំពស់ . អង្កត់ផ្ចិត ).កំនត់ប្រភេទឈើ.ចំនួនឈើ .គុណភាព -ដាក់ឡូតិ(៥មX៥ម) នៅក្នុងឡូតិ៍១០មX១០ម ដើម្បីរាប់វល្លិ៍ ផ្សិត ឱសថ សំណាកសត្វ - ដាក់ឡូតិ៍២មX២មនៅក្នុងឡូតិ៍៥មX៥មរាប់ដំនុះធម្មជាតិដែលទាបជាង២ម និងរាប់ប្រភេទលប់ និង គ្រាប់ពូជ

↓

**ការវិភាគទិន្នន័យសារពើភណ្ឌ**

-ប្រភេទឈើ
-ចំនួនឈើដែលមានក្នុងឡូតិ៍គិតជាហិចតា
-ការប្រើប្រាស់និងគ្រប់គ្រង

**[illegible]**

១-សេចក្តីផ្តើម:បង្ហាញពីស្ថានភាព.លើកឡើងនូវបញ្ហា . ចោទជាសំនួរនិងផ្តល់អនុសាសន៍

២-គោលបំណងនៃផែនការគ្រប់គ្រង :៣-ស្ថានភាពសហគមន៍: ឈ្មោះសហគមន៍,

ព្រំប្រទល់និងទីតាំង,សមាជិកសហគមន៍,គណៈកម្មាធិការ( រចនាសម្ព័ន្ធនិងបញ្ជីឈ្មោះ)

៤-ស្ថានភាពព្រៃឈើ:ឈ្មោះនិងប្រភេទព្រៃ.ទីតាំងនិងព្រំប្រទល់សហគមន៍ព្រៃឈើ( ភ្ជាប់ផែនទី) .ទំហំ

សហគមន៍ព្រៃឈើ.ប្រវត្តិព្រៃឈើ.ស្ថានភាពប្រើ ប្រាស់នាពេលបច្ចុប្បន្ន

៥-ការបែងចែកតំបន់អនុតំបន់;* តំបន់ទី១( ឈ្មោះមូលដ្ឋាន) .ផ្ទៃដី.ប្រភេទដី.ស្ថានភាពព្រៃ(Typolog·) .

ដំណុះធម្មជាតិ.គោលបំណង. ធនធានសំខាន់ៗ.ការប្រើប្រាស់( ការដកហូត-អាជីវកម្ម) .ការគ្រប់គ្រង

.លទ្ធផលសារពើភ័ណ្ឌ( លក្ខណៈព្រៃ.ប្រភេទឈើ.ស្តុក.អនុផល..)

៦-ការអភិវឌ្ឍន៍សហគមន៍: ការរៀបចំថ្នាល.ដាំឈើ.ធារាសាស្ត្រ.សាលារៀន

៧-ការអនុវត្តផែនការគ្រប់គ្រង:* តារាងផែនការសកម្មភាពប្រចាំឆ្នាំ

.ដាំឈើ.អាជីវកម្ម.ផ្លូវភ្លើង.ព្រំប្រទល់.ប្រជុំ * ការទទួលខុសត្រូវ * តួនាទីរបស់គណៈកម្មាធិការ

* ការត្រួតពិនិត្យវាយតំលៃ /តារាងឧបសម្ព័ន្ធ : ផែនទី , ឈ្មោះសហគមន៍ , លក្ខន្តិកៈ ។

**ពិនិត្យឡើងវិញផែនការគ្រប់គ្រង**

-រំលឹកឡើងវិញនូវសកម្មភាពដែលបានធ្វើផែនការគ្រប់គ្រង

-ការរាយបង្ហាញផែនការគ្រប់គ្រងដល់សហគមន៍

-ការកែសំរួលលើផែនការគ្រប់គ្រងជាមួយសហគមន៍

-ដាក់ជូនផែនការគ្រប់គ្រងទៅស្ថាប័នពាក់ព័ន្ធដើម្បីពិនិត្យនិងសំរេច

**ការត្រួតពិនិត្យនិងវាយតំលៃ**

-វាយតំលៃលើដំណើរការនៃសកម្មភាពគ្រប់គ្រង

-រៀបចំផែនការសកម្មភាពបន្ត

-កែសំរួលលើចំនុចខ្វះខាត



*ការគូរផែនទីដោយមានការចូលរួម :*

- -គូសផែនទីដោយដៃ លើក្រដាស់ , លើដីរាបស្មើ... ដើម្បីកំណត់ ទិស, ទីតាំង វត្ថុពិតនៅលើដី
- -គ្មានអាប់ ស៊ុស, អដោនេ និងមាត្រដ្ឋាន តែមានកំណត់សំគាស់

*ការចែងចែកតំបន់អនុតំបន់ :-*

- -ទៅតាមស្ថានភាពព្រៃ, ដំណុះឈើ ជាក់ស្តែង
- -ព្រំប្រទល់ធម្មជាតិ អូរ, ស្ទឹង , ផ្លូវរទេះ ...ជាចំណុចសំខាន់ ហើយងាយស្រួល ក្នុងការកំណត់ព្រំប្រទល់ព្រៃឈើ

☆ **តើអ្វីទៅដែលហៅថាផែនទី ?**

-ផែនទីគឺជាវត្ថុតាង ដែលតំណាងអោយវត្ថុពិតនៅលើផែនដី ដែលវត្ថុនោះមានទីតាំង . មានអាប់ស៊ីស . អរដោនេ ជាក់លាក់ និងមានចំណុចបង្ហាញទិសច្បាស់លាស់ មានមាត្រដ្ឋាន កាលបរិច្ឆេទ និងសញ្ញាសំគាល់ច្បាស់លាស់ ។

☆ **តើអ្វីទៅដែលហៅថាផែនទីដែលមានការចូលរួម ?**

-ផែនទីដែលមានការចូលរួម គឺជាការគូសផែនទីដោយដៃនៅលើក្រដាស លើដីរាបស្មើ...........ដើម្បីកំណត់ទិសដៅ ទីតាំងនិងវត្ថុពិតនៅលើ ផែនដី តែគ្មានបញ្ជាក់ពី អាប់ស៊ីស . អរដោនេ និងមាត្រដ្ឋាន ច្បាស់លាស់ឡើយ ។

☆ **លក្ខណៈចាំបាច់ក្នុងការគូសផែនទី :**

-ចំណងជើងផែនទី រួមទាំងអាស័យដ្ឋានតំបន់

-សញ្ញាព្រួញដើម្បីបង្ហាញទិស ( ជាទូទៅគេដាក់ទិសខាងជើងនៅផ្នែកខាងលើក្រដាស )

-និមិត្តសញ្ញាសំរាប់សំគាល់ចំណុចទាំងឡាយណាដែលចាប់អារម្មណ៍ ។

-ចំណងជើងរៀបរាប់អត្ថន័យនៃនិមិត្តសញ្ញា

-ដាក់ឈ្មោះ របស់ក្រុមអ្នកធ្វើផែនទី

-ដាក់ថ្ងៃ ខែ ឆ្នាំ គូស ។

☆ **គោលបំណង**

-ចង់ដឹងប្រភពពត៌មានផ្សេងៗនៅក្នុងតំបន់

-ដឹងពីទីតាំងច្បាស់លាស់ក្នុងតំបន់

-ដើម្បីជំរុញអោយមានការបង្កើត ទំនាក់ទំនងរវាងពត៌មាននានា

# ការរៀបចំផែនទីដោយមានការចូលរួម

*******

## ១.ទស្សនៈទូទៅ

ការគូសផែនទីពង្រាង ក្នុងគោលបំណងប្រើប្រាស់នូវការគូសផែនទីដោយដៃ និងកត់ត្រានូវពត៌មានស្តីពីលក្ខណៈរូបសាស្ត្រ និងលក្ខខ័ណ្ឌសង្គមផ្សេងៗដែលមិនប្រាកដនៅតាមផែនទីសាធារណៈ ។ បុគ្គលិកធ្វើការនៅមូលដ្ឋានអាចធ្វើជាទីប្រឹក្សា ឬជាអ្នកសំរបសំរួលជួយណែនាំសហគមន៍ក្នុងការរៀបចំគូរផែនទីពង្រាង ។

អ្វីទៅជាផែនទីពង្រាងដោយមានការចូលរួម ?

ការគូរផែនទីដោយមានការចូលរួម គឺជាការបង្កើតឡើងនូវការគូរផែនទីពង្រាង ដែលជាតំរូវការរបស់បុគ្គលិក ធ្វើការនៅមូលដ្ឋាន ដោយមានកិច្ចសហការណ៍ជាមួយសហគមន៍ដើម្បីរៀបចំ ផែនទីនេះបានផ្តល់នូវអ្វីៗដែលមិនទាន់បានដឹងឮ ឬការបង្កើតឡើងនូវផែនទីនោះ វាបានកត់ត្រានូវពត៌មានផ្សេងៗជាច្រើនអំពីលក្ខណៈរូបសាស្ត្រ និងលក្ខ័ណ្ឌសង្គម។ មិនដូចគ្នាទៅនឹងការគូរផែនទីពង្រាងទេ ដែលជាទូទៅបុគ្គលិកធ្វើការនៅមូលដ្ឋាន បានគូសផែនទីដោយផ្ទាល់ទៅលើសៀវភៅ ឬក៏

ដោយប្រើក្រដាសផ្ទិត ។ចំណែកការគូសផែនទីដោយមានការចូលរួម គឺដំបូងត្រូវគូសនៅលើដី ក្ដារខៀន ឬផ្ទាំងក្រដាសសរធំ ដោយអ្នកភូមិ ហើយបន្ទាប់មកត្រូវធ្វើការចំលងចូលទៅក្នុងសៀវភៅ ឬក៏ក្រដាសផ្ទិត ដោយបុគ្គលិកធ្វើការនៅមូលដ្ឋាន ។

ការគូរផែនទីដោយមានការចូលរួម មិនមែនផ្ដល់តែតំលៃជាពត៏មាន សំរាប់បុគ្គលិកធ្វើការនៅមូលដ្ឋានប៉ុណ្ណោះទេ វាអាច ត្រូវបានប្រើប្រាស់ ដើម្បីទំនាក់ទំនងជាដៃគូររវាងអ្នកភូមិ និងបុគ្គលិកធ្វើការនៅមូលដ្ឋាន និងផ្ដល់អំណាចទៅអោយអ្នកស្រុកក្នុងការទទួល ដើម្បីគ្រប់គ្រង និង ប្រើប្រាស់ធនធានរបស់សហគមន៍មួយដ៏ជាក់លាក់ ។

## ២. គោលបំណង

✡ ដើម្បីបង្កលក្ខណៈអោយសមាជិកសហគមន៍ធ្វើអត្តសញ្ញាណ កំណត់ទីតាំង និងបែងចែកព្រឹត្តិការណ៍របស់ធនធានពីអតីតកាល និងបច្ចុប្បន្នកាល ការបែងចែកសិទ្ធិកាន់កាប់ ប្រើប្រាស់ និងអោយសមាជិកសហគមន៍ បញ្ជាក់ពីសារៈសំខាន់ ។ ទីតាំងដែលប្រកបដោយគ្រោះថ្នាក់ ដូចជានៅតំបន់នានាដែលគេដឹងថាមានបទល្មើសច្បាប់ ការបំពុល ការកាប់បំផ្លាញព្រៃឈើ ការបំពុលសត្វព្រៃ.... ។ នោះត្រូវធ្វើអត្តសញ្ញាណប័ណ្ណ និង ធ្វើផែនទីកំណត់ចំណាំអោយបានច្បាស់លាស់ ។

✡ យល់ច្បាស់អំពីមូលហេតុក្នុងការធ្វើផែនទីដោយមានការចូលរួម ដែលសារៈសំខាន់សំរាប់ការធ្វើផែនការ ជាមួយសហគមន៍ក្នុងការគ្រប់គ្រងធនធានព្រៃឈើ ។

✡ ដើម្បីជំរុញអោយមានការបង្កើតទំនាក់ទំនងរវាងពត៌មាននានា និងទីតាំង" អាកាស" នៃពត៌មាននោះ (ឧទាហរណ៍ បង្កើតទំនាក់ទំនងដែលអាចមើលឃើញផលរវាងធនធាន និងបញ្ហាបំរុងកើតមាន)

## ៣. កំណត់សំគាល់នៅលើផែនទី

គ្រប់ផែនទីទាំងអស់ត្រូវបានបង្ហាញ :

✡ ចំណងជើងផែនទី រួមបញ្ចូលទាំងទីតាំងរបស់តំបន់នោះ

✡ សញ្ញាព្រួញបង្ហាញពីទិសដៅ ជាទូទៅទិសខាងជើងត្រូវបានកំណត់ដៅផ្នែកខាងលើផ្ទាំងក្រដាស

✡ ផែនទីត្រូវមានសញ្ញាសំគាល់ និមិត្តសញ្ញា ពាក្យ និងមានពេលខ្លះប្រើស្រមោលពណ៌ ដើម្បីបង្ហាញចំណុច ឬលក្ខណៈទាំងឡាយណាដែលគួរចាប់អារម្មណ៍

✡ កំណត់សំគាល់បង្ហាញពីអត្ថន័យរបស់និមិត្តសញ្ញា

✡ ដាក់ឈ្មោះអ្នកដែលរៀបចំផែនទី ថ្ងៃ ខែ ឆ្នាំ ។

## ៤. ការគូរផែនទីពង្រាង

✡ ជ្រើសរើសទីតាំងដោយមើលនូវស្ថានភាពភូមិសាស្ត្រ

✡ កំណត់សញ្ញាសំគាល់នៅលើផែនទីពង្រាង

✡ ពង្រាងលក្ខណៈដែលចាំបាច់ដ៏ទៃទៀតដូចជា ទីជំរក ទឹកជប់ ត្រពាំង កន្លែងឈើសំខាន់ៗ កិរិតសិទ្ធិចូលប្រើប្រាស់ តំបន់វាលទំនាបលិចទឹក តំបន់ចំការពនេចរ វាលស្មៅ ល្ពាក់ និងសិទ្ធិកាន់កាប់ តំបន់ ដែលមានទំនាស់.... ។

✡ សរសេរឈ្មោះ ឬដាក់ឈ្មោះដល់បណ្តាលក្ខណៈចំបងៗដូចជា ទីតាំងភូមិ ព្រំប្រទល់ព្រៃ ផ្លូវ តំបន់ អនុតំបន់ បង្គោលព្រំប្រទល់សំរាប់ ផ្លូវចេញចូល..... ។

✡ ធ្វើការពិនិត្យពិច័យ និងធ្វើអោយពត៌មានទាំងនោះប្រើការបានដោយប្រើប្រាស់ប្រភពពត៌មានផ្សេងៗបន្ថែម

⌘ **សំគាល់** : ផែនទីពង្រាងជាទូទៅពុំមានភាពសុក្រិត និងមានមាត្រដ្ឋានជាក់លាក់ បើធៀបទៅនឹងផែនទីដែល ផលិតចេញពីស្ថាប័នជំនាញផលិតផែនទី ។

## ៥-ការធ្វើផែនទីដោយមានការចូលរួមចំណេរិការឡើងដោយ

✡ អភិវឌ្ឍន៏ការយល់ដឹងជាមូលដ្ឋាននៃតំបន់ណាមួយ ដែលយើងនឹងត្រូវធ្វើផែនទី នៅតំបន់នោះជាមុនសិន

✡ ពេលវេលានៃការគូសផែនទីត្រូវជ្រើសរើសពេលវេលា យ៉ាងណាអោយវាសមស្របទៅតាមរដូវកាល និងកិច្ចការប្រចាំថ្ងៃរបស់សហគមន៍

✡ ជ្រើសរើសទីតាំងដែលអាចមើលឃើញតំបន់ដែលត្រូវគូសផែនទី

✡ ធ្វើការសំរេចចិត្តក្នុងការបង្ហាញ,កំណត់នូវពត៏មានទូទៅ,ពត៏មានលំអិត និងមាត្រដ្ឋាន

✡ ប្រមូលផ្តុំនូវក្រុមអ្នកពត៏មានសំខាន់រួមបញ្ចូលទាំងបុរស និងស្ត្រី

✡ រក្សាក្រុមអ្នកចូលរួមធ្វើផែនទីអោយមានចំនួនតិច

✡ ធ្វើការដាក់សញ្ញាសំគាល់នៅលើដី ឬ ក្រដាសសដើម្បីបង្ហាញពីលក្ខណៈចំបង និងទិដ្ឋភាពទាំងឡាយដូចជា ផ្លូវទឹក ភូមិ ព្រៃ តំបន់លិចទឹក និងសរសេរឈ្មោះពីលក្ខណៈ និងឈ្មោះតំបន់នោះលើក្រដាសតូចៗ ដាក់នៅក្បែរសញ្ញាសំគាល់ទាំងនោះ

✡ លើកទឹកចិត្ត អោយសហគមន៍ចូលរួមគូសផែនទី និងជួយបន្ថែមនូវចំណុចសំខាន់ៗដូចជា ផ្លូវទឹក តំបន់ព្រៃសំខាន់ៗ តំបន់សត្វព្រៃ រស់នៅច្រើន ។

☼ ចំលងផែនទីដែលបានពង្រាងចូលទៅក្នុងសៀវភៅ ដោយដាក់បញ្ចូលទាំងកំណត់សំគាល់ផង ។

## ៦. ការកត់ត្រានូវការធ្វើផែនទីដោយមានការចូលរួម

☼ ទីតាំងភូមិសាស្ត្រនៃព្រំប្រទល់

☼ ទីតាំង និងឈ្មោះនៃតំបន់និមួយៗ និងតំបន់មានជំលោះ តំបន់ការពារ និងតំបន់ដែលមានប្រភេទពិសេស

☼ ចំនួនផ្ទះ និងប្រភេទនៃប្រជាជន ដែលផ្លាស់ប្តូរទីតាំងក្នុងតំបន់ព្រៃឈើសហគមន៍

## ៧. ចំណុចត្រូវប្រុងប្រយ័ត្នរបស់ផែនទីដោយមានការចូលរួម

☼ មាត្រដ្ឋានជានិច្ចកាលមិនទៀងទាត់ និងសុក្រិតត្រឹមត្រូវទេ

☼ ការគូសផែនទីដោយមានការចូលរួម មិនត្រូវគូសដោយឡែកពីគ្នាទេ

☼ ចាំបាច់ត្រូវពិនិត្យផ្ទៀងផ្ទាត់នូវពត៏មានដែលបានប្រមូលបាន ។ល។

*ដំណើរការរៀបចំផែនការគ្រប់គ្រងសហគមន៍ព្រៃឈើ :-*

-ផែនការគ្រប់គ្រងសហគមន៍ព្រៃឈើ ធ្វើឡើងដោយមានការចូលរួមពីសហគមន៍មូលដ្ឋានជាម្ចាស់ ។

-មន្ត្រីសំរបសំរួល ជាអ្នកជួយសំរួលក្នុងកិច្ចការនេះ លើការរៀបចំ ពង្រាង , ពិភាក្សាកែលំអ និងសុំការឯកភាព ។





<u>តំបន់ឈើសំណង់ :</u>

✌ -ការបែងចែកតំបន់អនុតំបន់ មានសារៈសំខាន់ អោយយើង ងាយស្រួលក្នុងការគ្រប់គ្រង និងប្រើប្រាស់បានត្រឹមត្រូវ ។

✌ -ជាទំលាប់របស់ភូមិយើង ឈើសំណង់សំរាប់ប្រើប្រាស់ ជាលក្ខណៈគ្រួសារ ដូចជាផ្ទះ, សំភារៈកសិកម្ម ... ជាដើម ។


តំបន់វាលស្បូវត្រូវបាន
ការពារ និង គ្រប់គ្រង
តាមទំលាប់ នៃការ
ប្រើប្រាស់ជាប្រពៃណី
របស់សហគមន៍មូល
ដ្ឋានយើង ។

របៀបវាស់ដើមឈើ :-




រូបទី១: ចាក់កំប៉ា
វាស់ទំហំដើមនៅ
ចំណោចកំពស់១,៣មពីដី



រូបទី២:
- ចំណុចកំពស់នៅដដែល
- ឈរនៅទីជំរាលខ្ពស់







រូបទី៣+៤ :
-កំពស់វាស់ដដែល
-វាស់មែកណាដែលប្រើបាន




[illegible] ព្រៃឈើគឺជាការរាប់ដើមឈើ ដើម្បីប៉ាន់ប្រមាណសម្បត្តិធនធានដែលមាននៅ [illegible] ព្រៃឈើសហគមន៍ ។

[illegible] នៃវិធីសាស្ត្រធ្វើសារពើភ័ណ្ឌ ដោយការគូសឡូតិ៍ ៖ :-

| ឡូតិ៍ ១០ម គុណ ១០ម | ឡូតិ៍ : ៤ ម គុណ ៤ម | ឡូតិ៍ : ២ម គុណ ២ម |
|---|---|---|
| -រាប់ដើមឈើ មានកំពស់ ខ្ពស់ជាង ២ម<br>-ចំនួន, ឈ្មោះ, គុណភាព<br>- សំណាកសត្វ ... | - ពិភាក្សាការប្រើប្រាស់ ឈើ, វល្លិ, ផ្លែឈើ, ឱសថ | -ដំណុះធម្មជាតិ ក្រោម២ម<br>-ប្រភេទលប់នៃដំណុះឈើ |